# សេចក្តីប្រកាសព័ត៌មាន

គណៈប្រតិភូមួយក្រុមរបស់អ.វ.ត.ក ដឹកនាំដោយឯកឧត្តម ស៊ាន វិសុទ្ធ ប្រធានការិយាល័យរដ្ឋបាល និង លោក Knut Rosandhaug អនុប្រធានការិយាល័យរដ្ឋបាល បានចូលរួមក្នុងកិច្ចប្រជុំជាមួយនឹងក្រុមបណ្តារដ្ឋចាប់អារម្មណ៍នៅឯបុរីញូយ៉ក កាលពីថ្ងៃទី១៦ និង ទី២០ ខែមិថុនា ឆ្នាំ២០០៨។

ការពិភាក្សាជាផ្លែផ្កាត្រូវបានប្រព្រឹត្តធ្វើឡើងក្នុងបរិយាកាសមួយប្រកបដោយការស្តាបនាខ្ពស់ ដោយក្រុមម្ចាស់ជំនួយ គណៈប្រតិភូរបស់អ.វ.ត.ក និងមន្ត្រីជាន់ខ្ពស់មកពីអគ្គលេខាធិការដ្ឋានរបស់អង្គការសហប្រជាជាតិ បានពិភាក្សាទៅលើគំរោងថវិកាថ្មីដែលបានកែប្រែ ដែលក្នុងពេលនោះបានបង្ហាញជូនជាពីរផ្នែកៈ ក្នុងផ្នែក ទីមួយគឺគំរោងថវិកាសំរាប់រយៈពេលរហូតដល់ចុងឆ្នាំ២០០៩ និងផ្នែកទី២ រួមបញ្ចូលការបង្ហាញពីគំរោងតំរូវការផ្សេងៗក្នុងឆ្នាំ២០១០។ គំរោងថវិកាបង្ហាញថាមានការផ្លាស់ប្តូរនិងការពន្យល់បន្ថែមជាច្រើនដែលបាន ធ្វើឡើងឆ្លើយតបទៅតាមការលើកឡើងរបស់ម្ចាស់ជំនួយកាលពីពេលធ្វើបទបង្ហាញពីគំរោងថវិកាក្នុង ខែមករា ឆ្នាំ២០០៨។

នាពេលនេះអ.វ.ត.ក កំពុងស្វះស្វែងរកថវិកាជំនួយសំរាប់រយៈពេលរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៩ (ផ្នែកទី១) ។ ចំនួនថវិកាដែលត្រូវការនោះគឺ ៥០.៣ លានដុល្លាសហរដ្ឋអាមេរិក (៣៩.៥ លានដុល្លាសំរាប់ថវិកាខាងភាគី អ.ស.ប និង ១០.៨ លានដុល្លា សំរាប់ខាងភាគីកម្ពុជា)។ គំរោងថវិកាបង្ហាញសំរាប់ផ្នែកទី២របស់ទាំងភាគីអន្តរជាតិនិងភាគីកម្ពុជាគឺមានចំនួន ៣៧.៩ លានដុល្លាសហរដ្ឋអាមេរិក។

យោងតាមការសន្យាថាផ្តល់ជំនួយដល់ អ.វ.ត.ក រហូតមកដល់ពេលនេះ អ.វ.ត.ក ត្រូវការថវិកាចំនួន ប្រមាណ ៤៣.៧ លានដុល្លាបន្ថែមទៀតសំរាប់បន្តការងាររហូតដល់ចុងឆ្នាំ២០០៩ (៣៧.៧ លានដុល្លាសំរាប់ភាគីអ.ស.ប និង ៦.១ លានដុល្លាសំរាប់ភាគីកម្ពុជា)

គួរកត់សំគាល់ផងដែរថា គំរោងថវិកាដែលបានបង្ហាញដល់ក្រុមបណ្តារដ្ឋចាប់អារម្មណ៍គឺមានរួមបញ្ចូលចំនួន ១៥% សំរាប់ថវិកាបំរុងទុកសំរាប់ចំណាយបន្ថែមផ្សេងៗលើអ្វីដែលមិនបានគិតទុកជាមុន។ ម្ចាស់ជំនួយខ្លះបានសំនូមពរឲ្យដកចំនុចនេះចេញពីគំរោងថវិកាដោយចង់ឲ្យ អ.វ.ត.ក លើកសំណើផ្សេងទៀងក្នុងពេលដែលត្រូវការ។ ក្រុមបណ្តាប្រទេសចាប់អារម្មណ៍និងអគ្គលេខាធិការដ្ឋានអ.ស.ប កំពុងពិភាក្សាពីបញ្ហានេះនៅឯញូយ៉ក។

ម្ចាស់ជំនួយបានសំដែងនូវការគាំទ្រយ៉ាងខ្លាំងក្លាទៅលើការងាររបស់ អ.វ.ត.ក ដោយបានបញ្ជាក់យ៉ាងច្បាស់លាស់តាមរយៈការប្រកាសផ្តល់វិភាគទានលើទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាលជប៉ុនកាលពីថ្ងៃទី ១៧ ខែមិថុនា ដល់ភាគីកម្ពុជានូវទឹកប្រាក់ប្រមាណជិត ៣ លានដុល្លា រួមទាំងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការផ្តល់ចំនួនជិត ១ លានដុល្លាថែមទៀត។